គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ៦៦ ចេញផ្សាយថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣
No. 66 Released on January 18, 2023

# អត្ថបទប្រចាំសប្តាហ៍ | Weekly Article

## បរធនបាលកិច្ចសង្គម

## Social Trust




https://www.facebook.com/profile.php?id=100084361616566

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានផ្តល់ការចុះបញ្ជីដល់បរធនបាលកិច្ចសង្គមអង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ ដែលបានបង្កើតឡើងដោយធនាគារអេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុន ចារឌីន ម៉េថឹសិន។ បរធនបាលកិច្ចនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណង ជួយឧបត្ថម្ភដល់កុមារដែលនៅតាមទីជនបទ ឬតាមតំបន់ដាច់ស្រយាល និងតំបន់ដែលមានសភាពក្រលំបាក និងមិនមានលទ្ធភាពទទួលបានការអប់រំថ្នាក់បឋមសិក្សា និងអនុវិទ្យាល័យ អាចទទួលបានការអប់រំ និងបន្តការសិក្សាបាន។ ជាមួយគ្នានេះ អង្គការមូលនិធិអេស៊ីលីដា-ចារឌីនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៧។

យោងតាមច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) បរធនបាលកិច្ចសង្គម ត្រូវបានបង្កើតឡើងនៅពេលដែលបរធនបាលទាយក ធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅបរធនបាល ដើម្បីប្រើប្រាស់ជាប្រយោជន៍ទូទៅក្នុងសង្គម ដូចជាគោលបំណង វប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។

ក្រោយការបង្កើត និងចុះបញ្ជីបរធនបាលកិច្ចឱ្យមានអនុលោមភាពតាមច្បាប់ មូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ ត្រូវបានធានាការពារ និងត្រួតពិនិត្យដោយច្បាប់ទៅលើរាល់មូលនិធិដែលទទួលបានពីសប្បុរសជនសម្រាប់សកម្មភាពសង្គមកិច្ច និងមនុស្សធម៌របស់ខ្លួន។

សូមបញ្ជាក់ផងដែរថា ដើម្បីបំពេញអនុលោមភាពតាមច្បាប់ រាល់ការបង្កើតបរធនបាលកិច្ចទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំបង្កើត និងការអនុញ្ញាតចុះបញ្ជីពី **ន.ប.ធ.** ដោយអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាន។

On January 6, 2023, the Trust Regulator (TR) provided Social Trust Registration for the ACLEDA-Jardine Foundation for Education, established by ACLEDA Bank Plc. and Jardine Matheson Limited. This trust was established to support children in rural or remote areas and areas that are poor and do not have access to primary and secondary education, access to education, and continuing education. Meanwhile, the ACLEDA-Jardine Foundation registered with the Ministry of Interior on May 4, 2017.

According to the Law on Trust (2019), a social trust is established when the trustor donates/transfers his/her property to the trustee for general social use, such as cultural, educational, human, religious or scientific purposes.

Following the trust establishment and registration to comply with the law, the ACLEDA-Jardine Foundation for Education fund is legally protected and monitored on all funds received from philanthropists for its social and humanitarian activities.

Please be noted that in order to comply with the law, all trust establishments in the Kingdom of Cambodia must apply for establishment and registration with the TR in accordance with the Law on Trust and related regulations in force.

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- បទប្បញ្ញត្តិពាក់ព័ន្ធ

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.